

# តតែតីតី

Kong Sok Keng

Seng Visoth



កូនពពែមួយឈ្មោះពីពី កំពុងអង្គុយចាំផ្លូវម្តាយមកពីផ្សារ។ វាឃើញមិត្តរបស់វាកំពុងរត់លេងខាងក្រៅ តែវាសុខចិត្តអង្គុយញ៉ាំនំ។



រំពេចនោះម្ដាយវាមកដល់។ មេពពែ៖ «ម៉ែបានទិញខោថ្មីមួយឱ្យកូនស្លៀកចូលឆ្នាំថ្មី។» ពីពី៖ «ជយោ! ខ្ញុំមានខោថ្មីស្លៀកចូលឆ្នាំហើយ!...» មេពពែបន្ត៖ «ម៉ែមានដំណឹងល្អមួយទៀតសម្រាប់កូន ។» នេះជាក្រដាសប្រកាសអំពី ការប្រឡងរត់ប្រណាំងនៅថ្ងៃចូលឆ្នាំ។ តើកូនចង់ចូលរួមទេ? ពីពី៖ «អត់ទេម៉ែ កូនមិនចង់រត់ទេ។»



បន្ទាប់មកពីពីបានស្លៀកខោថ្មីទៅបង្ហាញពុកវាដែលកំពុងដាំបន្លែនៅក្រោយផ្ទះ។ កំពុងតែរត់ស្រាប់តែខ្វាក...! ពីពី៖ «អុញ! ខោរហែកបាត់។» ពីពីធ្វើមុខស្រពោន។



ពីពីរត់ទៅផ្លាស់ខោវិញ។ ពីពី៖ «ហ៊ឺ... ! ខោថ្មីរបស់ខ្ញុំរហែកបាត់ហើយ។»



ពីពីបានរត់ទៅជួបម្ដាយ៖ «ម៉ែ ខោថ្មីកូនរហែកហើយ។ តើម៉ែជួយដេរឱ្យកូនបានទេ?» ម៉ែ៖ «ទេ ម៉ែកំពុងរវល់ រៀបចំអីវ៉ាន់សម្រាប់ថ្ងៃចូលឆ្នាំ។»



ពីពីបានទៅជួបឪពុក៖ «ពុក! តើពុកជួយដេរខោឱ្យកូនបានទេ?» ពុកពីពី៖ «បាន! តែកូនត្រូវទៅរកម្ជុល និង អំបោះឱ្យពុកសិន។»









ពីពីបានរត់ទៅរកតែរកអំបោស និងម្ជុល គ្រប់ទីកន្លែង។ ពីពីរកក្នុងថតតុ ពីពីរកក្នុងទូ ពីពីរកលើទូ ពីពីរកក្នុងកញ្ជើដែរ។



ពីពីហត់គឃ្លាស។ វារត់ទៅប្រាប់ពុកវាវិញ។ ពុកពពែ៖ «តើកូនរកម្ហូល និងអំបោះឃើញទេ?» ពីពី៖ «មិនឃើញទេពុក ហើយខ្ញុំហត់ណាស់។ កូនឈឺជង្គង់ ឈឺខ្នង និងហត់ខុសធម្មតា។» ពុក៖ «កូនមិនសូវធ្វើចលនាខ្លួនប្រាណ គឺបែបនេះហើយ។»



ពីពីអង្គុយសោកសៅហើយនឹកទៅដល់កូនស្វា និងកូនស្វា
ដែលតែងរត់ហាត់ប្រាណ នៅក្នុងភូមិរាល់ព្រឹក។ វាមិនចូលចិត្ត
ហាត់ប្រាណទេ តែវាគិតថាការហាត់ប្រាណប្រហែលជាអាចជួយ
វាបាន។



ពីពីក៏សម្រេចចិត្តទៅហាត់ប្រាណជាមួយកូនស្វា និងកូនឆ្កែ។ វារត់យឺត កូនឆ្កែនិងកូនស្វារត់លឿន។ កូនស្វា និងកូនឆ្កែរត់ខាងមុខ ពីពីរត់ខាងក្រោយ។ ពីពីខំប្រឹងរត់ហើយរត់ទៀត រត់! រត់! រត់.....



ដោយអស់កម្លាំងពេក ភ្លាមនោះពីពី រអិលជើងដួលប្រូស...
អូយ!... កូនស្វា និងកូនឆ្កែនាំគ្នាលើកពីពីឡើង។



ថ្ងៃបន្ទាប់ ពីពីមិនចង់ទៅរត់លេងទៀតទេ ព្រោះឈឺជង្គង់ និង ខ្លួនប្រាណខ្លាំង។ ពុករបស់ពីពីថា៖ «លើកដំបូងវាមានអការៈបែបនេះ តែពីរបីថ្ងៃទៀតលែងអីហើយ។» កូនពពែក៏សម្រេចចិត្តថាទៅរត់បន្តទៀត។



មិត្តទាំងបីលេងជាមួយគ្នាយ៉ាងរីករាយ។ ពេលខ្លះពួកគេរត់ប្រណាំង ពេលខ្លះលេងទាត់បាល់ ពេលខ្លះលេងទាត់សី ។ ពីពីឈប់ឈឺជង្គង់ និង ឆាប់ហត់ដូចមុនទៀតហើយ។ ពេលនេះវាមានសុខភាពល្អជាមុន។



ថ្ងៃចូលឆ្នាំថ្មីចូលមកដល់។ ពីពីបានសម្រេចចិត្តចូលរួម រត់ប្រណាំង ជាមួយមិត្តដទៃក្នុងភូមិ។ ពីពីស្រែកថា៖ ជយោ! ខ្ញុំ អាចរត់បានលឿនជាងមុន។




បន្ទាប់ពីការប្រកួតរត់ប្រណាំង ពីពីបានស្លៀកខោថ្មីដែលម៉ែទិញឱ្យ ដើម្បីដើរលេងចូលរួមបុណ្យចូលឆ្នាំថ្មីយ៉ាងរីករាយ។





Generously supported by SMART

# Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*ពពែពីពី (Pipi the Goat)*, Author: Kong Sok Keng. Illustrator: Seng Visoth. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/